# សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ ( សូជី )នៅក្នុងកិច្ចប្រជុំ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់( យូ.ភី.អ )

## ជុំទី១ (ឆ្នាំ២០០៨-២០១២)

អនុសាសន៍អំពីសូជី ចំនួន៥០២ ត្រូវបានផ្តល់ឱ្យជាសកល ដោយ៣៥ប្រទេស ទៅកាន់១៣៥ប្រទេស

អនុសាសន៍ អំពីសូជីចំនួន0 បានផ្តល់មកប្រទេសកម្ពុជា

## ជុំទី២ (ឆ្នាំ២០១៣-២០១៧)

អនុសាសន៍អំពីសូជី ចំនួន៩៥៨ ត្រូវបានផ្តល់ឱ្យជាសកល ដោយ៣៥ប្រទេស ទៅកាន់១៣៥ប្រទេស

អនុសាសន៍អំពីសូជី ចំនួន0 បានផ្តល់មកប្រទេសកម្ពុជា

## ជុំទី៣ (ឆ្នាំ២០១៨-ថ្ងៃទី០១ ខែ០២ ឆ្នាំ២០១៩)

អនុសាសន៍អំពីសូជី ចំនួន២៥៨ ត្រូវបានផ្តល់ឱ្យជាសកល ដោយ ៤០ប្រទេស ទៅកាន់២៦ប្រទេស

អនុសាសន៍អំពីសូជី ចំនួន៩ បានផ្តល់មកប្រទេសកម្ពុជា

# សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ ( សូជី ) នៅក្នុងកិច្ចប្រជុំ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ( យូ.ភី.អ )

## សម្រាប់ប្រទេសកម្ពុជាជុំទី៣

អនុសាស្ដន៍ចំនួន ១៦៩ បានផ្តល់ឱ្យដោយ៧៣ប្រទេស មកកាន់កម្ពុជា អំពីស្ថានភាពផ្សេងៗគ្នា

អនុសាសន៍អំពី សិទ្ធិសូជី ចំនួន ៩ ស្មើនឹងចំនួន៥.៣៣% នៃចំនួនអនុសាសន៍ទាំងអស់

មាន ៧ ប្រទេសដែលបានផ្តល់អនុសាសន៍ទាំងនោះដូចជា

- អូស្ត្រាលី
- កាណាដា
- អ៊ីស្លង់ (មានចំនួន ៣ អនុសាសន៍ )
- ម៉ិចស៊ីកូ
- ហូឡង់
- ស៊ុយអ៊ែត
- និងអ៊ុយរូហ្គាយ

មានបញ្ហា ៣ ដែលផ្តោតទៅលើ

- បង្កើតឱ្យមានគោលនយោបាយស្តីពី ការប្រឆាំងនឹងការរើសអើង ឬបង្កើតឱ្យមានការការពារដល់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា( មានចំនួន៥អនុសាសន៍ )
- វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញដើម្បីអនុញ្ញាតអោយមានអាពាហ៍ពិពាហ៍សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា (មានចំនួន ៣ អនុសាសន៍ )
- បង្កើតអោយមានច្បាប់ទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់អ្នកស្រលាញ់ភេទដូចគ្នា (មានចំនួន ១ អនុសាសន៍ )

# សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ ( សូជី ) នៅក្នុងកិច្ចប្រជុំ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ( យូ.ភី.អ )

## សម្រាប់ប្រទេសកម្ពុជាជុំទី៣

## អនុសាសន៍អំពី "ការប្រឆាំងនឹងការរើសអើងចំពោះអ្នកស្រលាញ់ភេទដូចគ្នា"

### អូស្ត្រាលី

ត្រឹមឆ្នាំ២០២៣ បង្កើតឱ្យមានច្បាប់ស្តីពី ការប្រឆាំងនឹងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា ដែលធានាភាពស្មើគ្នា និងហាមឃាត់រាល់ទម្រង់នៃការរើសអើងទាំងអស់ ដែលរួមបញ្ចូលនិងជំនឿជាមូលដ្ឋាន និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ។

### អ៊ីស្លង់

បង្កើតឱ្យមានច្បាប់ស្តីពី ការប្រឆាំងនឹងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា ដែលធានា និងហាមឃាត់រាល់ទម្រង់ នៃការរើសអើងទាំងអស់ដែលរួមបញ្ចូលជាមូលដ្ឋាន នៃនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ។

### ម៉ិចស៊ីកូ

រៀបចំកិច្ចពិភាក្សាជាមួយអង្គការសង្គមស៊ីវិល ទៅលើគោលនយោបាយ និងច្បាប់ដែលទូលំទូលាយពី ការប្រឆាំងនឹងការរើសអើង និងអំពើហិង្សាលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ហើយធានាអំពី ការអនុវត្តនៅគ្រប់សាធារណជនទាំងមូល ជាពិសេសក្នុងវិស័យអប់រំ សុខភាព និងការងារ។

### ស៊ុយអ៊ែត

បង្កើតឱ្យមានច្បាប់ថ្មី ដែលធានាអំពីភាពស្មើគ្នា និងហាមឃាត់ ចំពោះការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា។

### អ៊ុយរូហ្គាយ

រៀបចំវិធីសាស្ត្រដែលមានប្រសិទ្ធិភាព ដើម្បីរួមបញ្ចូល និងការដាក់ទោសទណ្ឌ ចំពោះការរើសអើង និងការប្រើអំពើហិង្សាដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

# សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ (សូជី) នៅក្នុងកិច្ចប្រជុំ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ)

## សម្រាប់ប្រទេសកម្ពុជាជុំទី៣

### អនុសាសន៍មួយចំនួនអំពី “អាពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នា”

**កាណាដា**

វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាត្តិឱ្យ ដៃគូភេទដូចគ្នាអាចរៀបការបាន។

**អ៊ីស្លង់**

វិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីធានាចំពោះភាពស្មើគ្នា នៃការរៀបអាពាហ៍ពិពាហ៍ដៃគូភេទដូចគ្នា។

**ហូឡង់**

វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ ដើម្បីទទួលបានភាពស្មើគ្នា នៃការរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងការបន្តការយកចិត្តទុកដាក់ស្មើគ្នា ចំពោះប្រជាជនអ្នកស្រលាញ់ភេទដូចគ្នា នៅគ្រប់តំបន់។

កំណត់ចំណាំ: មាត្រា ៤៥នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បានចែងថា
ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។
ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់។
បុរស និងស្ត្រីមានសិទ្ធិស្មើគ្នា ក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។
អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយ ប្រពន្ធមួយ។

# សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ (សូជី)
# នៅក្នុងកិច្ចប្រជុំ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ)
## សម្រាប់ប្រទេសកម្ពុជាជុំទី៣

## អនុសាសន៍អំពី "ការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ"

### អ៊ីស្លង់

តាក់តែងច្បាប់ស្ដីពី ការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ របស់អ្នកស្រលាញ់ភេទដូចគ្នា។

## អនុសាសន៍ដទៃទៀតដែលទាក់ទងនឹងបញ្ហានេះ

មានអនុសាសន៍ជាក់លាក់មួយចំនួន ដែលបានផ្ដល់ឱ្យប្រទេសកម្ពុជាអំពី ភាពស្មើគ្នានៃយេនឌ័រ របស់ស្ត្រី និងសិទ្ធិរបស់កុមារផងដែរ ដែលទាក់ទងនឹងយន្តការរបស់ច្បាប់អន្តរជាតិ និងនិតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ដែលបានអនុវត្តសម្រាប់បុគ្គល ដែលជាអ្នកស្រលាញ់ភេទដូចគ្នា។ ជាពិសេស មានរដ្ឋដែលជា សមាជិករបស់អង្គការសហប្រជាជាតិជាច្រើន បានផ្ដល់អនុសាសន៍មកកម្ពុជា ដើម្បីឱ្យមានការទទួលស្គាល់ពីដំណើរការ នៃវត្តមាននិតិវិធីពិសេស របស់អង្គការសហប្រជាជាតិ ដែលរួមបញ្ចូលអ្នកជំនាញឯករាជ្យទទួលបន្ទុកផ្នែកសូជី របស់អង្គការសហប្រជាជាតិ ដែលបានស្នើសុំទស្សនកិច្ច មកកាន់កម្ពុជា តាំងពីឆ្នាំ២០១៨ ដែលស្ថិតនៅក្នុងដំណាក់កាលរង់ចាំ។

# សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវយេនឌ័រ និងលក្ខណៈភេទ (សូជី) នៅក្នុងកិច្ចប្រជុំ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) សម្រាប់ប្រទេសកម្ពុជាជុំទី៣

## សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា

"រដ្ឋាភិបាលកម្ពុជាត្រូវតែជាប្រទេសឈានមុខក្នុងការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា និងលុបបំបាត់រាល់ទម្រង់នៃការរើសអើង ចំពោះសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការធ្វើវិសោធនកម្មច្បាប់រដ្ឋប្បវេណីឱ្យមានភាពស្របច្បាប់ចំពោះការអនុវត្តផ្សេងៗ ទាមទារឱ្យមានការតស៊ូមតិ និងការផ្សព្វផ្សាយចំណេះដឹង ទៅដល់សាធារណជនជាចាំបាច់។ ដើម្បីធានានូវការទទួលស្គាល់ពិតប្រាកដពីសង្គមនិងសហគមន៍ដែលអាចកាត់បន្ថយប្រតិកម្មបែបវប្បធម៌ ហើយធ្វើឱ្យច្បាប់ដែលត្រូវបានវិសោធនកម្មមានលក្ខណៈត្រឹមត្រូវ។"

ឯកឧត្តម កែវ រ៉េមី ជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាប្រធានដឹកនាំគណៈប្រតិភូនៃកិច្ចប្រជុំយូ.ភី.អ

សម្រង់ប្រសាសន៍របស់ឯកឧត្តម ដែលបានថ្លែងទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩